**បទបញ្ជាថ្នាក់លើ (superior order)**

មូលដ្ឋាននេះ មិនជួយឲ្យរួចផុតពីការទទួលខុសត្រូវទេ ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (international criminal law)។ ជាក់ស្តែងមាត្រា៦.៤ នៃលក្ខន្តិកៈ ICTR ចែងថា៖ ការណ៍ដែលជនត្រូវចោទធ្វើសកម្មភាពតាមបញ្ជារបស់រដ្ឋាភិបាល ឬថៅហ្វាយនាយ មិនអាចដោះឲ្យរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ ក៏ប៉ុន្តែអាចជាស្ថានសម្រាល ប្រសិនបើ តុលាការគិតថា យុត្តិធម៌តម្រូវឲ្យធ្វើដូចនេះ។

មាត្រា៣៣នៃលក្ខន្តិកៈ ICC ចែងលម្អិតបន្ថែមថា លើការដោះសារ៖ បុគ្គលមានកាតព្វកិច្ច គោរពបញ្ជា បុគ្គលមិនដឹងថា បទបញ្ជា ជាបទបញ្ជាខុសច្បាប់ ហើយបទបញ្ជានោះ មិនខុសច្បាប់ដែលអាចមើលឃើញយ៉ាងក្រឡែត (not manifestly unlawful)។ បទបញ្ជាឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ (genocide) គឺខុសច្បាប់។

ទីនេះគេមានការលំបាកបន្តិចក្នុងកិច្ចការងារយោធា ពីព្រោះទាហាន ត្រូវបានគេបង្រៀន ឲ្យគោរពបទបញ្ជា ហើយវានឹងពិបាកណាស់ ក្នុងការរកពេលពិចារណា ថាបទបញ្ជាណាមួយខុស ឬត្រូវច្បាប់ ក្នុងពេលមានសង្គ្រាម។ ម្យ៉ាងទៀត គេពិបាកជឿថា ទាហាន សក្តិទាបជាមនុស្សមានការពិចារណាល្អ (man of common sense) ដូចទាហាន ដែលជាថ្នាក់ដឹកនាំ។ វាជាការល្អដែរ ដែលតុលាការសឹក នឹងមិនដាក់ទោស អ្នកដែលមិនគោរពបទបញ្ជាខុសច្បាប់។

យុត្តិសាស្ត្រ មិនទទួលយកការដោះសារនេះទេ ក្នុងករណីដែល គាត់ទទួលបទបញ្ជាប្រព្រឹត្តបទព្រហ្មទណ្ឌ និងអនុវត្តជាមួយចេតនាទុច្ចរិតរបស់ខ្លួន (malice)។

បទបញ្ជាថ្នាក់លើនេះ អាចពាក់ព័ន្ធនឹងការដោះសារ ការច្រឡំផ្លូវច្បាប់ (mistake of law) ក្នុងន័យថា ទាហានបានយល់ថា បទបញ្ជានេះស្របតាមច្បាប់ ដែលពេលខ្លះ ការពិតមិនដូចនេះទេ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 525-527)។